# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិអេស្កាប់**

### សេចក្តីប្រកាសព័ត៌មាន
### ស្តីពី
### កិច្ចពិគ្រោះយោបល់គោលនយោបាយលើរបាយការណ៍សេដ្ឋកិច្ច និងសង្គម នៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ឆ្នាំ២០២៤

**ឯកឧត្តមទេសរដ្ឋមន្ត្រី លី ធុជ** ប្រធានគណៈកម្មាធិការជាតិអេស្កាប់ (គ.ជ.អ.ស) បានអញ្ជើញជាអធិបតីក្នុង **កិច្ចពិគ្រោះយោបល់គោលនយោបាយលើរបាយការណ៍សេដ្ឋកិច្ច និងសង្គមនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិកឆ្នាំ២០២៤** ដែលរៀបចំដោយគណៈកម្មាធិការជាតិអេស្កាប់ និងគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ (UN-ESCAP) ប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤ នាសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។ កិច្ចពិគ្រោះយោបល់នេះ មានចូលរួមថ្លែងសុន្ទរកថាពីលោក Hamza Ali Malik នាយកទទួលបន្ទុកផ្នែកគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍរបស់ UN-ESCAP និងលោកស្រី Alissar Chaker តំណាងអង្គការ UNDP ប្រចាំកម្ពុជា និងមានការចូលរួមពីឧត្តមមន្ត្រី និងមន្ត្រីជំនាញរបស់រាជរដ្ឋាភិបាលកម្ពុជា បញ្ញវន្ត ដៃគូអភិវឌ្ឍន៍ ព្រមទាំងមន្ត្រីជំនាញរបស់ UN-ESCAP។

នាឱកាសនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី លី ធុជ** បានថ្លែងថា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យរបស់ **សម្តេចអគ្គមហាសេនាតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាល បានគ្រប់គ្រង និងប្រើប្រាស់បំណុលសាធារណៈ យ៉ាងមានប្រសិទ្ធភាព ដែលក្នុងនោះ ភាគច្រើននៃកម្ចីដែលទទួលបាន មានលក្ខណៈជាសម្បទាន និងត្រូវបានប្រើប្រាស់សម្រាប់អភិវឌ្ឍវិស័យអាទិភាព ដែលគាំទ្រដល់កំណើនសេដ្ឋកិច្ចរយៈពេលវែងប្រកបដោយចីរភាព និងបង្កើនផលិតភាពសេដ្ឋកិច្ច។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងផងដែរថា បន្ទាប់ពីការសម្រេចបាននូវសុខសន្តិភាពពេញលេញ ឯកភាពជាតិ និង ឯកភាពទឹកដីទាំងស្រុង តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចតេជោ ហ៊ុន សែន** រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តប្រកបដោយជោគជ័យនូវ **យុទ្ធសាស្ត្រត្រីកោណ** និង**យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** ដោយសម្រេចបានសមិទ្ធផលធំៗ លើគ្រប់វិស័យទាំងនយោបាយ សង្គម និងសេដ្ឋកិច្ច ដែលនាំកម្ពុជាឱ្យសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈបំផុត។ ឯកឧត្តម បានបន្ថែមថា លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដោយកំណត់យកអាទិភាពគន្លឹះចំនួន ៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង** និង **បច្ចេកវិទ្យា**។

អាសយដ្ឋាន: ទីស្តីការគណៈរដ្ឋមន្ត្រី អគារមិត្តភាព ជាន់ទី៤ បន្ទប់លេខ៤២៦ មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០២៣ ២១៩ ២០៦ ទូរសារលេខ: ០២៣ ២២០ ៨៣៤ អ៊ីម៉ែល: info@nc-escap.gov.kh គេហទំព័រ: www.nc-escap.gov.kh

ឯកឧត្តម បានគូសបញ្ជាក់ថា អស់រយៈពេលជាង ១១ ខែ រាជរដ្ឋាភិបាលបានដាក់ចេញនូវគំនិតផ្តួចផ្តើមជាច្រើនជាពិសេស លើវិស័យសុខាភិបាល ការបណ្តុះបណ្តាលវិជ្ជាជីវៈ សុខុមាលភាព ការងារ ការដោះស្រាយទំនាស់ សកម្មភាពអាកាសធាតុ និងផ្សេងៗទៀត។ រាជរដ្ឋាភិបាលកម្ពុជាបន្តប្តេជ្ញាថានឹង "**មិនទុកនរណាម្នាក់ចោល**" និងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីជួយដល់ក្រុមដែលខ្វះខាត និងងាយរងគ្រោះ ដើម្បីធានាឱ្យប្រជាជនទាំងអស់ទទួលបានអត្ថប្រយោជន៍ពីវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាននូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

ឯកឧត្តមបានបន្ថែមថា ដំណាក់កាលទីមួយនៃយុទ្ធសាស្ត្របញ្ចកោណ ដែលបាន និងកំពុងអនុវត្តបានផ្តល់នូវអត្ថប្រយោជន៍ចំពោះប្រជាពលរដ្ឋ ជាពិសេសចំពោះប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។ ជីវភាពរស់នៅរបស់ពួកគាត់បានប្រសើរឡើង ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចបាននូវឋានៈចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឋានៈប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។

ជាចុងក្រោយ ឯកឧត្តម បានលើកឡើងថា សមិទ្ធផលនានាដែលកម្ពុជាសម្រេចបាន គឺអាស្រ័យដោយសន្តិភាព និងស្ថិរភាព ដែលបានកសាងឡើង និងការពារដោយរាជរដ្ឋាភិបាលកម្ពុជា និងការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ ជាពិសេសស្ថាប័ននានារបស់អង្គការសហប្រជាជាតិ រួមមាន UN-ESCAP និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ផងដែរ។

ឯកឧត្តម បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គការសហប្រជាជាតិ ជាពិសេស UN-ESCAP និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដែលបានចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការកសាងសន្តិភាពនិងស្ថិរភាព និងការការពារបរិស្ថាននៅកម្ពុជា។ ឯកឧត្តម បានគូសបញ្ជាក់ថា កម្ពុជាប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការជាមួយ UN-ESCAP ហើយការចូលរួមរបស់ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** នៅក្នុងសន្និបាតប្រចាំឆ្នាំលើកទី៨០ របស់ UN-ESCAP នាពេលថ្មីៗនេះ គឺជាសក្ខីភាពនៃការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាមួយគ្នានេះ ឯកឧត្តម បានលើកឡើងជាពិសេសថា កម្ពុជាបាន និងកំពុងបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រឹងប្រែងជាសកលក្នុងការដោះស្រាយបញ្ហា ការប្រឈម និងគ្រោះថ្នាក់នានាដែលគំរាមកំហែងដល់សន្តិភាព សន្តិសុខ របៀបរបបអន្តរជាតិមួយដែលផ្អែកលើច្បាប់ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ជាចុងបញ្ចប់ **ឯកឧត្តមទេសរដ្ឋមន្ត្រី លី ធុជ** បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះឧត្តមមន្ត្រី និងមន្ត្រីជំនាញរបស់រាជរដ្ឋាភិបាលកម្ពុជា បញ្ញវន្ត ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ព្រមទាំងមន្ត្រីជំនាញរបស់ UN-ESCAP ដែលបានចំណាយពេលដ៏មានតម្លៃរបស់ខ្លួនចូលរួម និងផ្តល់ធាតុចូលយ៉ាងសកម្មនៅក្នុងកិច្ចពិគ្រោះយោបល់នេះ។

ថ្ងៃចន្ទ ១០កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

អាសយដ្ឋាន៖ ទីស្តីការគណៈរដ្ឋមន្ត្រី អគារមិត្តភាព ជាន់ទី៤ បន្ទប់លេខ៤២៦ មហាវិថីសហព័ន្ធរុស្សី រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ ០២៣ ២១៩ ២០៦ ទូរសារលេខ៖ ០២៣ ២២០ ៨៣៤ អ៊ីមែល: info@nc-escap.gov.kh គេហទំព័រ: www.nc-escap.gov.kh